ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ២២៩០ ព.ណ.ក.ព...

ថ្ងៃ ចន្ទ ១៥រោច ខែ អាសាឍ ឆ្នាំ ជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០២០

**សូមគោរពជូន**

**ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី**
**ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
**និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនា ភូមិ១ ផលិតផល១**

**កម្មវត្ថុ៖** របាយការណ៍វឌ្ឍនភាពការងារ និងលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០២០ របស់ក្រុមការងារជំរុញចលនា ភូមិ១ ផលិតផល១ (ក.ក.ភ១.ផ១) ក្រសួងពាណិជ្ជកម្ម។

**យោង ៖** លិខិតលេខ ៤៧៩ សជណ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាសេនាធិការរបស់គណៈកម្មាធិការជាតិជំរុញចលនាភ១ ផ១ បានរៀបចំផែនការសកម្មភាពការងាររយៈពេល ៥ឆ្នាំ (២០១៩-២០២៣) សម្រាប់ចូលរួមអនុវត្តចលនានេះ។ ខ្ញុំបាទ សូមការអនុញ្ញាតគោរពរាយការណ៍ជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ពីវឌ្ឍនភាពការងារ និងលទ្ធផលប្រចាំឆមាសទី១ ឆ្នាំ២០២០ (មករា-មិថុនា) ដោយសង្ខេបដូចខាងក្រោម៖

១. ការងារគោលនយោបាយជាតិស្តីពីផលិតផលខ្មែរ

ក. គោលនយោបាយជំឡូងមីកម្ពុជា៖ ក្រសួងបានរៀបចំ និងចូលរួមកិច្ចប្រជុំអន្តរក្រសួងចំនួន ៣លើក នៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ ផ្តល់ធាតុចូលបំពេញបន្ថែម លើសេចក្តីព្រាងគោលនយោបាយជំឡូងមីបានចប់សព្វគ្រប់។ សេចក្តីព្រាងគោលនយោបាយនេះ គ្រោងនឹងដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាពេលដ៏ខ្លីខាងមុខនេះ។

ខ. គោលនយោបាយម្រេចកម្ពុជា៖ ក្រសួងពាណិជ្ជកម្ម សហការជាមួយដៃគូអភិវឌ្ឍន៍ បាននិងកំពុងបន្តពិនិត្យឡើងវិញលើសេចក្តីព្រាងគោលនយោបាយម្រេចកម្ពុជា ដោយអនុលោមតាមទម្រង់គតិយុត្តនៃគោលនយោបាយជំឡូងមី ដែលកំណត់ដោយទីស្តីការគណៈរដ្ឋមន្ត្រី។ ក្រុមការងារអន្តរក្រសួង កំពុងបន្តរៀបចំគោលនយោបាយនេះ។

គ.គោលនយោបាយស្វាយចន្ទីកម្ពុជា៖ ក្រសួងពាណិជ្ជកម្ម សហការជាមួយដៃគូអភិវឌ្ឍន៍ និងក្រុមការងារអន្តរក្រសួង បន្តរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសចំនួន ២លើក ដើម្បីពិនិត្យពិភាក្សា និងផ្តល់ធាតុចូលក្នុងរបាយការណ៍គាំទ្ររបស់ជំនាញការអន្តរជាតិ ដើម្បីតាក់តែងសេចក្តីព្រាងគោលនយោបាយស្វាយចន្ទីនេះ។ របាយការណ៍គាំទ្រ ទទួលបានឯកភាពពីក្រុមការងារ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០។

២. សិក្សាស្រាវជ្រាវបច្ចេកវិទ្យានវានុវត្តន៍(Innovation)សម្រាប់ជំរុញ និងលើកកម្ពស់ផលិតផលខ្មែរ

- ដើម្បីលើកកម្ពស់ផលិតផលខ្មែរ ក្រសួងពាណិជ្ជកម្ម បានសហការជាមួយមន្ទីរពាណិជ្ជកម្មខេត្តដូចជា សៀមរាប កំពង់ចាម បាត់ដំបង កំពត កំពង់ស្ពឺ និងរតនគិរី បង្កើតផ្សារចុងសប្តាហ៍ ដើម្បីតាំងលក់ផលិតផលបន្លែ ផ្លែឈើខ្មែរសុវត្ថិភាព ស្រូវអង្ករ និងសាច់មាន់ស្រែ និងផលិតផលកសិ-ពាណិជ្ជកម្ម ដទៃទៀតដែលផលិតក្នុងភូមិ ស្រុក ក្នុងខេត្តនីមួយៗ ដែលមានអ្នកចូលរួមសរុបចំនួន ១ ៧៧០នាក់ និងមានស្តង់សរុប ៧៦ ស្តង់។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- បានរៀបចំពិធីសម្ពោធដាក់ឲ្យដំណើរការផ្សារអាហារសុវត្ថិភាពរបស់ក្រុមហ៊ុន ខេ.ស៊ី.ស៊ី.វី ផ្លេនថេសិន សហការជាមួយគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMS លើផលិតផលកសិ-ពាណិជ្ជកម្ម បន្លែ និងមាន់ស្រែ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២០។

- ការងារសំខាន់ៗដែលសម្រេចបានទាក់ទងនឹងវិស័យសូត្រៈ

- បានរៀបចំព្រឹត្តិការណ៍សូត្រ និងតម្បាញកម្ពុជាចំនួន ០២លើករួចមកហើយ នាខេត្តសៀមរាប។
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការបង្កើតម៉ាកសមូហភាពសូត្រខ្មែរ និងយុទ្ធសាស្ត្រវិស័យសូត្រកម្ពុជា ២០១៦-២០២០ នៅខេត្តសៀមរាប តាកែវ បន្ទាយមានជ័យ និងរាជធានីភ្នំពេញ។
- បានរៀបចំកម្មវិធីចុះអនុស្សរណៈយោគយល់គ្នាជាមួយក្រុមហ៊ុនជីអេសឌី ភាច ឯ ក.( GSD PHEACH CO.,LTD ) អភិវឌ្ឍខ្សែចង្វាក់តម្លៃសូត្រខ្មែរ។

**៣. រៀបចំបណ្តុះបណ្តាលមន្ត្រីជំនាញ និងសហគ្រិន ស្តីពីការរៀបចំប្រព័ន្ធត្រួតពិនិត្យគុណភាព និង សុវត្ថិភាព**

ក្រសួងពាណិជ្ជកម្ម បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីជំនាញពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាព បានចំនួន ៥វគ្គគឺៈ

- វិធីសាស្ត្រ នៃការយកសំណាកគំរូផលិតផល-ទំនិញ ដែលមានមន្ត្រីជំនាញចូលរួមចំនួន ១២០នាក់។

- ការពង្រឹងការអនុវត្តអនុក្រឹត្យ ១៣៣ និងវិធីសាស្ត្រត្រួតពិនិត្យ និងវាយតម្លៃអនុលោមភាព ចំនួន២វគ្គ ដែលមានមន្ត្រីចូលរួមចំនួន ៦០នាក់។

- ការលើកកម្ពស់ការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងការងារកូដិចនៅកម្ពុជា ដែលមានមន្ត្រីជំនាញចូលរួមចំនួន ៤០នាក់។

- កិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងទីផ្សារ និងការទប់ស្កាត់ការក្លែងបន្លំ"ម្រេចកំពត" ដោយមានអ្នកចូលរួមចំនួន ៥២នាក់។

**៤. ផ្តល់ការប្រឹក្សាយោបល់ ដើម្បីគាំទ្រនិងលើកកម្ពស់សមត្ថភាពសហគ្រាសផលិតកម្ម និងផលិតផលខ្មែរ លើការវេចខ្ចប់ និងគំនូរឧស្សាហកម្ម**

ក- ការបង្កើតម៉ាកសមូហភាព "អំបុកឃុំសាន់គរ" ខេត្តកំពង់ធំ ដោយបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកសាងម៉ាកយីហោ "អំបុក" ជាម៉ាកសមូហភាព នៅស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានអ្នកចូលសរុប ១០៩នាក់។ ក្រសួងសហការជាមួយតំណាងក្រុមផលិតករបណ្តោះអាសន្ន ដើម្បីរៀបចំចងក្រងសៀវភៅគ្រប់គ្រងការប្រើប្រាស់ម៉ាករួម បទបញ្ជាផ្ទៃក្នុង និងកំណត់យកយីហោ "អំបុក" ដើម្បីកសាង ជាម៉ាកសមូហភាព "អំបុកឃុំសាន់គរ"។

ខ- បានបង្កើតរចនាសម្ព័ន្ធគ្រប់គ្រងគម្រោងថ្នាក់តំបន់ ស្តីពី ការលើកកម្ពស់ និងទទួលស្គាល់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញសម្រាប់ប្រទេសកម្ពុជា ឡាវ និងភូមា ដែលគម្រោងមានរយៈពេលបីឆ្នាំ គិតចាប់ពីពាក់កណ្តាលឆ្នាំ ២០១៩ ដល់ ២០២២ ទៅលើផលិតផលអំបិល ផ្កាអំបិលកំពត ស្ករត្នោតកំពង់ស្ពឺ។

**៥. ការសិក្សាស្រាវជ្រាវផលិតផល ដែលមានហានិភ័យ ប៉ះពាល់សុវត្ថិភាពអ្នកប្រើប្រាស់**

ក្រសួងបានសិក្សាស្រាវជ្រាវលើផលិតផលដែលមានហានិភ័យ ប៉ះពាល់សុវត្ថិភាពអ្នកប្រើប្រាស់ ចំនួន ៤៦ ផលិតផល ដោយក្នុងនោះ ផលិតផលដែលមានហានិភ័យខ្ពស់មានចំនួន ១១ផលិតផល ផលិតផលដែលមានហានិភ័យមធ្យមមានចំនួន ១១ផលិតផល និងផលិតផលដែលមានហានិភ័យទាបមានចំនួន ២៤ផលិតផល។

**៦. រៀបចំបង្កើត និងចងក្រងឯកសារប្រព័ន្ធត្រួតពិនិត្យគុណភាព និងសុវត្ថិភាពម្ហូបអាហារ**

ក្រសួង បានរៀបចំប្រកាសលេខ២៦៣ ព.ណ.អ.គពទ.ប្រក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពី ការកំណត់នីតិវិធីនៃការនាំចូលម្ហូបអាហារ ដើម្បីជាឯកសារគតិយុត្តក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាព។

**៧. ផ្សព្វផ្សាយច្បាប់ ស្តីពីស្តង់ដារកម្ពុជា ច្បាប់ និងបទប្បញ្ញត្តិបច្ចេកទេសនានា**

កាលពីខែមេសា ឆ្នាំ២០២០ ក្រសួងបានចេញនូវតម្រូវការថ្មីសម្រាប់ម្ចាស់ម៉ាក និងភ្នាក់ងារតំណាងស្របច្បាប់នៃម៉ាកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាក ចុះបញ្ជីម៉ាកសាជាថ្មី ការផ្លាស់ប្តូរផ្សេងៗ និងឯកសារពាក់ព័ន្ធ តាមប្រព័ន្ធអេឡិចត្រូនិក ដោយសារការរីករាលដាលនៃជំងឺរាតត្បាតជំងឺកូវីដ១៩ ។

**៨. វេទិកាផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន ស្តីពីទស្សនទាន ទីផ្សារ និងការងារពាក់ព័ន្ធនានានៃចលនាភូម១ ផលិតផល១**

- បានរៀបចំប្រព័ន្ធផ្សព្វផ្សាយតាមរយៈគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មចំនួន៤លើក និងតាមរយៈវិទ្យុជាតិចំនួន៤០៥ដង អំពីពិព័រណ៍ផលិតផលខ្មែរក្នុងឱកាសបុណ្យទន្លេនៅខេត្តបាត់ដំបង និងយុទ្ធនាការទិញផលិតផលខ្មែរនៅខេត្តមណ្ឌលគីរី បន្ទាយមានជ័យ និង សៀមរាប (កម្មវិធីនេះត្រូវបានលុបចោលវិញ)។

- បានរៀបចំ និងចូលរួមពិព័រណ៍ផលិតផលខ្មែរក្នុងឱកាសបុណ្យទន្លេនៅខេត្តបាត់ដំបង ដែលប្រព្រឹត្តទៅចាប់ពីថ្ងៃ១២-១៥ ខែមីនា ឆ្នាំ២០២០នៅទីក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានស្តង់សរុបចំនួន៤៩០ស្តង់ ក្នុងនោះស្តង់ផលិតផលខ្មែរមានចំនួន២២០ស្តង់។

- បានរៀបចំ និងចូលរួមពិព័រណ៍ ASEAM Day ដែលបានដាក់តាំងបង្ហាញផលិតផលខ្មែរចំនួន១ស្តង់ក្នុងកម្មវិធីដ៏សំខាន់នោះផងដែរ។

**៩. ការងារបង្កើតមជ្ឈមណ្ឌលតាមសហគមន៍ លើកកម្ពស់ចលនាភូមិ១ ផលិតផល១**

-បានរៀបចំវេទិកាជាតិ ស្តីពី "**ការជំរុញ និងអភិវឌ្ឍន៍វិស័យស្ទូនដីកម្ពុជា**" ដើម្បីចងក្រងឯកសារពាក់ព័ន្ធ ដូចជាគោលការណ៍ណែនាំស្តីពីផលិតកម្ម រចនាសម្ព័ន្ធផ្នែកទន់ ដោយបានតាមដានការងារនេះជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ក្នុងគោលបំណងស្នើសុំជំនួយពី CBI ដើម្បីរៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ លើផលិតផលស្ទូនដីកម្ពុជា នៅខេត្តកំពង់ឆ្នាំង។

- ត្រៀមរៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ ផលិតផល១ លើចម្លាក់ថ្មកែវកម្ពុជា នៅខេត្តពោធិ៍សាត់។ ក្រសួងបានស្នើមន្ទីរពាណិជ្ជកម្មខេត្តពោធិ៍សាត់ សហការជាមួយមន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ចុះផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងពីគោលដៅរបស់ក្រសួងពាណិជ្ជកម្ម ក្នុងការជួយគាំទ្រ និងជំរុញការអភិវឌ្ឍផលិតផលសក្តានុពលចម្លាក់ថ្មកែវកម្ពុជា។

-ក្រសួងបានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីត្រៀមរៀបចំបង្កើតមជ្ឈមណ្ឌលភូមិ១ផលិតផល១ លើចម្លាក់ប្រាក់-ស្ពាន់ខ្មែរ នៅស្រុកពញាឮ ខេត្តកណ្តាល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងមេត្តាផ្តល់អនុសាសន៍ណែនាំដោយអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានទី១**
**នៃគណៈកម្មាធិការជាតិជំរុញចលនា ភ១ ផ១**

ប៉ាន_សូរស័ក្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ:**..៤៧៨...ស.ជ.ណ

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១៧*

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**សូមគោរពជូន**

- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី**
- **លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ** : ករណីរបាយការណ៍ស្តីពីការផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពី ការជំរុញចលនាភូមិមួយផលិតផលមួយ ២០១៦ -២០២៦ កាលពីថ្ងៃទី ៦ ខែមេសា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។

**យោង** : - លិខិតលេខ ១៩៣ ក.ក.ជ ចុះថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

- ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧។

តបតាមកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **សម្តេច ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា : ដើម្បីជំរុញការងារចលនាភូមិមួយ ផលិតផលមួយ កាន់តែមានសន្ទុះខ្លាំងក្លា និងមានសមិទ្ធផលធំធេង ស្របតាមគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយឆ្នាំ ២០១៦-២០២៦ រាជរដ្ឋាភិបាលបានសម្រេចឯកភាពលើ ០៥ចំណុច ដូចខាងក្រោម៖

១.គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរជារៀងរាល់ឆ្នាំ ដែលទិវាជាតិនេះត្រូវប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែមេសា មុនការរៀបចំពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់យើង ដើម្បីឲ្យប្រជាជនយើងបានយល់ដឹងនិងទិញទំនិញប្រើប្រាស់ជាផលិតផលខ្មែរ នៅក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីជាតិរបស់យើង។

២.ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ នៅក្នុងស្ថាប័នរបស់ខ្លួនដើម្បីរួមសហការជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ ដែលជាសេនាធិការជូនគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ។

៣.ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយ ផលិតផលមួយ ត្រូវសហការគ្នារៀបចំផែនការនិងយុទ្ធសាស្ត្ររួមគ្នាឲ្យមានប្រសិទ្ធភាពខ្ពស់ និងការប្រជុំចែករំលែកបទពិសោធដើម្បីដោះស្រាយបញ្ហានិងការប្រឈមនានា ក្នុងការលើកកម្ពស់ផលិតផលខ្មែរ និងការយល់ដឹងនិងប្រើប្រាស់ផលិតផលខ្មែរ។

៤.គណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយរាជធានី-ខេត្ត ទូទាំងប្រទេស ដែលបានរៀបចំបង្កើតកាលពីឆ្នាំ២០១៤ ត្រូវសហការឲ្យបានជិតស្និទ្ធជាមួយនឹងអគ្គលេខាធិការដ្ឋានភូមិមួយ ផលិតផលមួយក្នុងស្មារតីទទួលខុសត្រូវខ្ពស់នៃការខិតខំលើកកម្ពស់ផលិតផលខ្មែរ ក្នុងដែនសមត្ថកិច្ចរាជធានី-ខេត្តរបស់ខ្លួន ដោយប្រើប្រាស់យន្តការនានា និងធនធានថវិការបស់សាលាខេត្ត និងមន្ទីរវិស័យពាក់ព័ន្ធក្នុងការចូលរួមជំរុញនិងលើកកម្ពស់ផលិតផលខ្មែរក្នុងរាជធានីខេត្តរបស់ខ្លួន។

៥.ក្នុងគោលដៅលើកកម្ពស់ផលិតផលក្នុងស្រុក សូមឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជួយបង្កើនកញ្ចប់ថវិកាជាតិដល់គណៈកម្មាធិការជាតិ ក៏ដូចជាគណៈកម្មាធិការរាជធានី-ខេត្តជំរុញចលនាភូមិមួយផលិតផលមួយ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការជំរុញចលនាភូមិមួយផលិតផលមួយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវ មេត្តាជ្រាប និងចាត់ចែងអនុវត្តតាមការគួរ។

**ឧ.រដ្ឋមន្ត្រីស្តីទីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ម៉ុន_អ៊ុំយ

**ចម្លងជូន** :

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្តទាំង២៥
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-សភាពាណិជ្ជកម្មកម្ពុជា
-សភាមុខរបរនិងមីក្រូសហគ្រាស
-កាកបាទក្រហមកម្ពុជា
ឯកសារ កាលប្បវត្តិ